Khmer | ភាសាខ្មែរ

# ជំនួយពិតប្រាកដ។ ឥឡូវនេះ។



## ប្រាក់ឧបត្ថម្ភលើកទឹកចិត្តលើការសន្សំសំចៃថាមពល $100៖ របៀបដាក់ពាក្យសុំ

ការផ្តល់ជំនួយពិតប្រាកដសម្រាប់ការចំណាយក្នុងការរស់ដល់ពលរដ្ឋវិចថូរៀដែលត្រូវការវាច្រើនបំផុត។

រដ្ឋាភិបាលរដ្ឋវិចថូរៀ កំពុងផ្តល់ជំនួយពិតប្រាកដដើម្បីដោះស្រាយការចំណាយក្នុងការរស់ និងកាត់បន្ថយវិក្កយបត្រថាមពលសម្រាប់ពលរដ្ឋវិចថូរៀដែលខ្វះខាត ជាមួយនឹងប្រាក់ឧបត្ថម្ភលើកទឹកចិត្តលើការសន្សំសំចៃថាមពលថ្មី $100។

ចាប់ពីថ្ងៃទី 25 ខែសីហា ឆ្នាំ 2025 អ្នកកាន់ប័ណ្ណសម្បទានដែលមានសិទ្ធិទទួលបានអាចដាក់ពាក្យសុំប្រាក់រង្វាន់លើកទឹកចិត្តដោយចូលមើលគេហទំព័រ Victorian Energy Compare (ប្រៀបធៀបថាមពលរដ្ឋវិចថូរៀ) ខណៈពេលដែលពិនិត្យមើលថាពួកគេកំពុងស្ថិតនៅក្នុងផ្តល់ជូនថាមពលដ៏ល្អបំផុតឬអត់។

Victorian Energy Compare (ប្រៀបធៀបថាមពលរដ្ឋវិចថូរៀ) គឺជាគេហទំព័រដែលគ្រប់គ្រងដោយរដ្ឋាភិបាលដោយឥតគិតថ្លៃ និងឯករាជ្យ ដែលធ្វើឱ្យវាងាយស្រួលក្នុងការប្រៀបធៀបការផ្តល់ជូនអគ្គិសនី ឧស្ម័ន និងថាមពលពន្លឺព្រះអាទិត្យ។ ដោយប្រើគេហទំព័រនេះដើម្បីត្រួតពិនិត្យ និងប្តូរគម្រោងថាមពលជាប្រចាំ នោះពលរដ្ឋអាចសន្សំប្រាក់បានយ៉ាងច្រើនលើការចំណាយថាមពលរបស់ពួកគេ។

អ្នកមិនចាំបាច់ប្តូរទៅគម្រោងថាមពលផ្សេង ដើម្បីមានលក្ខណៈគ្រប់គ្រាន់សម្រាប់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តលើការសន្សំសំចៃថាមពល $100 នោះទេ។ គ្រាន់តែប្រើគេហទំព័រដើម្បីប្រៀបធៀបគម្រោងនានាដែលមាន – វារហ័ស ងាយស្រួល និងអាចជួយអ្នកស្វែងរកកិច្ចព្រមព្រៀងប្រសើរជាងមុន។

### ប្រាក់ឧបត្ថម្ភលើកទឹកចិត្តលើការសន្សំសំចៃថាមពល $100

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តលើការសន្សំសំចៃថាមពល $100 គឺជាការបង់ប្រាក់តែមួយដងដែលបានរៀបចំឡើងដើម្បីជួយគ្រួសារទាំងឡាយដែលមានសិទ្ធិទទួល ដើម្បីគ្រប់គ្រងវិក្កយបត្រថាមពលនៅរដូវរងា និងសម្រួលដល់ការចំណាយក្នុងការរស់នៅ។

ដោយប្រើគេហទំព័រប្រៀបធៀបថាមពលរដ្ឋវិចថូរៀ (Victorian Energy Compare) ដើម្បីដាក់ពាក្យសុំ នោះអ្នកអាចរកឃើញការសន្សំថ្មីៗ និងទទួលបានប្រាក់រង្វាន់លើកទឹកចិត្ត $100 ខណៈពេលដែលអ្នកធ្វើការប្រៀបធៀប។

### សិទ្ធិទទួលបាន

ដើម្បីមានសិទ្ធិទទួលបាន គ្រួសារនានានឹងត្រូវ៖

- មានវិក្កយបត្រអគ្គិសនីលំនៅដ្ឋានថ្មីៗ
- កាន់ប័ណ្ណសម្បទានមួយក្នុងចំណោមប័ណ្ណសម្បទានខាងក្រោម៖
  – ប័ណ្ណថែទាំសុខភាព
  – ប័ណ្ណសម្បទានប្រាក់សោធននិវត្តន៍
  – ប័ណ្ណសម្បទានប្រាក់សោធននិវត្តន៍របស់អតីតយុទ្ធជន
  – ប័ណ្ណពណ៌មាសរបស់អតីតយុទ្ធជន

ប្រាក់ឧបត្ថម្ភតែមួយប៉ុណ្ណោះក្នុងមួយគ្រួសារ។

### របៀបដាក់ពាក្យសុំ

ដើម្បីដាក់ពាក្យសុំ សូមចូលមើលគេហទំព័រ Victorian Energy Compare (compare.energy.vic.gov.au) ឬដាក់ពាក្យសុំតាមទូរសព្ទ (**1800 000 832**) ឬដោយជួបផ្ទាល់តាមរយៈផ្ទះសុវត្ថិភាពអ្នកជិតខាង (neighbourhood houses) ដែលចូលរួម។

VICTORIAN ENERGY COMPARE

VICTORIA State Government

# ជំនួយពិតប្រាកដ។ ឥឡូវនេះ។

## អ្វីដែល Victorian Energy Compare អាចធ្វើបានសម្រាប់អ្នក៖

- វាប្រៀបធៀបការផ្តល់ជូនដែលមាន ជាមួយគម្រោងបច្ចុប្បន្នរបស់អ្នក ដូច្នេះអ្នកអាចដឹងថាតើការផ្តល់ជូនទាំងនោះមានតម្លៃខ្ពស់ជាង ឬទាបជាង។
- គេហទំព័រនេះស្វែងរករាល់ការលក់ជូននៅលើទីផ្សារ ពីគ្រប់អ្នកលក់រាយថាមពលរដ្ឋវិចថូរៀ។
- វាបង្ហាញអ្នកនូវការផ្តល់ជូនប្រាក់បង់ដោយរដ្ឋាភិបាលសម្រាប់ការប្រើថាមពលដែលផលិតចេញពីពន្លឺព្រះអាទិត្យ។
- វាប្រើទិន្នន័យជាក់លាក់សមស្របនឹងគ្រួសារ ឬអាជីវកម្មរបស់អ្នក ដើម្បីផ្តល់ព័ត៌មានដ៏ល្អបំផុត។

**1** រកមើលវិក្កយបត្រអគ្គិសនីចុងក្រោយបំផុតរបស់អ្នក។

**2** ចូលមើលគេហទំព័រ compare.energy.vic.gov.au

**3** បញ្ចូលព័ត៌មានរបស់អ្នក និងស្វែងរកការលក់ជូនដ៏ល្អបំផុត។

### ប្រៀបធៀប ហើយសន្សំសំចៃប្រាក់

ពលរដ្ឋដែលបានប្រើគេហទំព័រ Victorian Energy Compare (ប្រៀបធៀបថាមពលរដ្ឋវិចថូរៀ) នៅទូទាំងឆ្នាំ 2024 អាចសន្សំប្រាក់បានច្រើនជាង $240 ដោយប្តូរទៅការផ្តល់ជូនដែលមានតម្លៃល្អបំផុត។

### លំនៅដ្ឋាន និងអាជីវកម្មខ្នាតតូច

Victorian Energy Compare (ប្រៀបធៀបថាមពលរដ្ឋវិចថូរៀ) មានការផ្តល់ជូនថាមពលជាទូទៅសម្រាប់អ្នកប្រើប្រាស់ថាមពលតាមលំនៅដ្ឋាន និងអាជីវកម្មខ្នាតតូច។

### បញ្ចុះតម្លៃ 17.5%

អ្នកកាន់ប័ណ្ណសម្បទានអាចមានសិទ្ធិទទួលបានការបញ្ចុះតម្លៃ 17.5% លើវិក្កយបត្រអគ្គិសនីរបស់ពួកគេពេញមួយឆ្នាំ និងវិក្កយបត្រឧស្ម័ននៅរដូវរងា (ខែឧសភា-ខែតុលា)។

គេហទំព័រថាមពលរបស់រដ្ឋាភិបាលរដ្ឋវិចថូរៀ ផ្តល់ព័ត៌មានអំពីការងារដែលយើងកំពុងធ្វើជាមួយឧស្សាហកម្ម និងសហគមន៍ ដើម្បីបង្កើតអនាគតថាមពលប្រកបដោយសន្តិសុខ និងនិរន្តរភាពរបស់រដ្ឋវិចថូរៀ។



## ចូលមើល energy.vic.gov.au/households

© ក្រសួងថាមពល បរិស្ថាន និងសកម្មភាពអាកាសធាតុ នៃរដ្ឋវិចថូរៀ ខែសីហា ឆ្នាំ 2025

**ISBN** 978-1-76176-542-1 **(Print)**
**ISBN** 978-1-76176-543-8 **(pdf/online/MS word)**

**ការបដិសេធមិនទទួលខុសត្រូវ**
ការបោះពុម្ពផ្សាយនេះអាចជាជំនួយដល់អ្នក ប៉ុន្តែរដ្ឋវិចថូរៀ និងនិយោជិតរបស់ខ្លួនមិនធានាថាការបោះពុម្ពនេះគ្មានកំហុសណាមួយ ឬសមស្របទាំងស្រុងសម្រាប់គោលបំណងជាក់លាក់របស់អ្នកទេ ដូច្នេះហើយរដ្ឋវិចថូរៀបដិសេធការទទួលខុសត្រូវទាំងអស់ចំពោះកំហុស ការបាត់បង់ ឬផលវិបាកផ្សេងទៀតណាមួយដែលអាចកើតឡើងពីអ្នក ដែលពឹងផ្អែកលើព័ត៌មានណាមួយនៅក្នុងការបោះពុម្ពផ្សាយនេះ។

សម្រាប់ជំនួយជាភាសាក្រៅពីភាសាអង់គ្លេស សូមទាក់ទងសេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS) តាមទូរសព្ទលេខ 131 450។

VICTORIA State Government

2052